**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
**លេខ ១៦០ គ.ជ.ប/អគ្គ/ប្រ.ក.ព**

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ៣:០០រសៀល នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប និងឯកឧត្តម **គួយ ប៊ុនរឿន** អនុប្រធាន គ.ជ.ប បានទទួលជួបឯកឧត្តម **ចច អេដហ្គឺ** (H.E. Mr. George Edgar) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត និងការជួយគាំទ្រ គ.ជ.ប ជាបន្តទៀត។

បន្ទាប់ពីឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប បានពន្យល់អំពីការងារមួយចំនួនរបស់ គ.ជ.ប ជុំវិញដំណើរការបោះឆ្នោតរួចមក ឯកឧត្តម **ចច អេដហ្គឺ** (H.E. Mr. George Edgar) បានលើកឡើងដោយចង់ដឹងអំពីចំនួនបណ្តឹង ក្នុងដំណាក់កាលបោះឆ្នោត និងការដោះស្រាយបណ្តឹងនៅ គ.ជ.ប តើមានការប្រព្រឹត្តទៅយ៉ាងដូចម្តេច?

ឆ្លើយតបនឹងករណីនេះ ឯកឧត្តម **ស៊ិក ប៊ុនហុក** មានប្រសាសន៍ថា គ.ជ.ប បានទទួល និងដោះស្រាយលើបណ្តឹងចំនួន ៦៤ ក្នុងនោះមាន ៖

- ១៨បណ្តឹង ជាបណ្តឹងផ្តន្ទាទោស
- ៤៦បណ្តឹង ជាបណ្តឹងសុំរាប់សន្លឹកឆ្នោតឡើងវិញ។

ក្នុងចំណោមបណ្តឹងសុំរាប់សន្លឹកឆ្នោតឡើងវិញទាំង ៤៦ មាន ៣បណ្តឹង ត្រូវបាន គ.ជ.ប សម្រេចលើកយកមកដោះស្រាយ ក្នុងនោះមាននៅឃុំដូង ខេត្តស្វាយរៀង ឃុំបឹងប្រាំ ខេត្តបាត់ដំបង និងឃុំក្លែង ខេត្តកំពង់ធំ ដោយសារតែបណ្តឹងទាំងនោះ មានលក្ខណៈត្រឹមត្រូវស្របតាមមាត្រា១៤៩ និងមាត្រា១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ឯកឧត្តម **ចច អេដហ្គឺ** (H.E. Mr. George Edgar) មានប្រសាសន៍ថា រហូតមកដល់ពេលនេះសហភាពអឺរ៉ុប (EU) មិនទាន់ចេញសេចក្តីថ្លែងការណ៍ផ្លូវការណាមួយចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅឡើយទេ ប៉ុន្តែ EU គាំទ្រសេចក្តីថ្លែងការណ៍របស់ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ហើយសេចក្តីថ្លែងការណ៍ផ្លូវការរបស់ EU នឹងចេញបន្ទាប់ពី គ.ជ.ប ប្រកាសលទ្ធផលនៃការបោះឆ្នោតផ្លូវការ។ ឯកឧត្តមបន្តថា EU នឹងបន្តជួយ គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោតនៅឆ្នាំ២០១៨ បន្តទៀត។

ចុងបញ្ចប់នៃកិច្ចប្រជុំភាគីទាំងពីរបានសន្យាថា នៅដើមខែសីហា ឆ្នាំ២០១៧ នឹងជួបគ្នាជាថ្មីម្តងទៀត ដើម្បីពិភាក្សាការងារបន្ត។

ទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh